# សុន្ទរកថារបស់ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ
# ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុន
# ប្រចាំព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីសម្ពោធអគារសិក្សាមួយខ្នងនៅអនុវិទ្យាល័យ អារុណវតី
# រាជធានីភ្នំពេញ

ថ្ងៃទី ២៤ ខែធ្នូ ២០១៥

-សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
-សូមគោរព ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ
-សូមគោរពឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោកស្រី និងអស់លោកទាំងអស់

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានមកចូលរួមក្នុងពិធីសម្ពោធអគារសិក្សាថ្មីមួយខ្នងនៅអនុវិទ្យាល័យអារុណវតី ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ។

ការធានាឲ្យបាននូវសិទ្ធិទទួលបានការអប់រំសម្រាប់សិស្សានុសិស្សទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺពិតជាសំខាន់ណាស់សម្រាប់ការអភិវឌ្ឍប្រទេស។ ខ្ញុំសូមសម្តែងនូវសេចក្តីគោរពយ៉ាងស្មោះសរចំពោះការប្តេជ្ញាចិត្ត និង កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកែកម្មវិស័យអប់រំ។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃវិស័យអប់រំក្នុងការអភិវឌ្ឍធនធានមនុស្ស រដ្ឋាភិបាលជប៉ុនបាន និងកំពុងបន្តគាំទ្រកម្ពុជាតាមរយៈការសាងសង់អគារសិក្សា និងបណ្តុះបណ្តាលគ្រូបង្រៀនតាំងពីទស្សវត្សឆ្នាំ១៩៩០មកម្ល៉េះ។

ទាក់ទងទៅនឹងការអប់រំនៅកម្រិតអនុវិទ្យាល័យ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិចំនួន១៨ហើយ នៅរាជធានីភ្នំពេញ។ ហើយគម្រោងថ្ងៃនេះសម្រាប់អនុវិទ្យាល័យអារុណវត្តីគឺជាគម្រោង ទី១៩។ នៅពេលឆាប់ៗខាងមុខនេះ រដ្ឋាភិបាលនឹងផ្តួចផ្តើមគម្រោងថ្មីមួយទៀតដែលមានឈ្មោះថា "គម្រោងពង្រីកសាលាអនុវិទ្យាល័យក្នុងរាជធានីភ្នំពេញ" ដែលអនុវត្តដោយJICA។ ហើយពិធីបញ្ចុះបឋមសិលានឹងប្រព្រឹត្តទៅនៅ ខែមករាឆ្នាំក្រោយដោយគម្រោងនេះរួមមានការប្រគល់អគារអនុវិទ្យាល័យចំនួន៨ ស្មើនឹង១៦៥បន្ទប់ជូនរាជធានី។

ខ្ញុំបានដឹងថា សិស្សានុសិស្សនៃអនុវិទ្យាល័យអារុណវតី ត្រូវសិក្សាក្នុងថ្នាក់រៀនដែលមានសិស្ស

រួមថ្នាក់ចំនួនលើសពី៥០នាក់ ដោយសារកង្វះបន្ទប់រៀន។ ការសាងសង់អគារសិក្សាថ្មីដែលមាន៧បន្ទប់ និងបំពាក់សង្ហារឹមគ្រប់គ្រាន់នេះ នឹងជួយអោយសិស្សានុសិស្សអាចសិក្សានៅក្នុងថ្នាក់រៀនមានចំនួនសិស្សសមស្របទៅតាមនិយាមគរុកោសល្យ។ ជាងនេះទៅទៀត គម្រោងនេះនឹងជួយឲ្យមានការសិក្សាពេញម៉ោងក្នុង១ថ្ងៃ ហើយអាចអោយសិស្សានុសិស្សអនុវត្តម៉ោងសិក្សាពី៣២ ទៅ៣៥ម៉ោងក្នុងមួយសប្តាហ៍តាមការណែនាំរបស់ក្រសួងអប់រំ យុវជននិងកីឡា។

ខ្ញុំសង្ឃឹមដោយស្មោះសរថាអាគារសិក្សានិងគ្រឿងសង្ហារឹមថ្មីដែលបំពាក់ជូននេះនឹងត្រូវបាន ថែរក្សាយ៉ាងល្អ និងគង់វង្ស ហើយខ្ញុំក៏សង្ឃឹមដែរថា អគារនេះ នឹងក្លាយជានិមិត្តរូបនៃទំនាក់ទំនងមិត្តភាពរវាងជប៉ុន និងកម្ពុជា សម្រាប់រយៈពេលច្រើនឆ្នាំបន្តទៅទៀត។

ជាចុងក្រោយ ខ្ញុំសូមសំដែងនូវការកោតសរសើរដោយស្មោះអស់ពីដួងចិត្តចំពោះលោក-អ្នកទាំងអស់ដែលបានចូលរួមចំណែកក្នុងការអនុវត្តគម្រោងនេះ អាចសម្រេចទៅបានដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណ!